00162833

**Declassified to Public**
**06 September 2012**

ការ/ស:D22/15

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / FEB / 2008
ម៉ោង (Time/Heure): 16:00'
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUN VICHET

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des co-juges d'instruction

សំណុំរឿងព្រហ្មទណ្ឌ
Criminal Case File /Dossier pénal
លេខ/No 001/18-07-2007

លេខស៊ើបសួរ/Investigation/Instruction
លេខ/No: 001/18-07-2007

# កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី
# Written Record of Interview of witness
# Procès-verbal d'audition de témoin

ច្បាប់ចម្លងដែលបានបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 02 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឆ្នាំពីរពាន់ប្រាំពីរ ខែវិច្ឆិកា ថ្ងៃទីមួយ នៅវេលាម៉ោងប្រាំបួនព្រឹកនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

យើង សឹម សុរិយ៉ា(សស), និង Fabienne Luco (FL) ជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានចាត់ដោយដីកាចាត់អោយស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៧។

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤
បានឃើញវិធាន ២៤ ២៨ និង៦០ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

☒ ដោយមានវត្តមានរបស់ លោក ហេង ហាំខេង ជាអ្នកបកប្រែភាសារបស់អង្គជំនុំជម្រះវិសាមញ្ញដែលបានស្បថរួចហើយ។

បានកត់ត្រាយកចម្លើយពីឈ្មោះ ញ៉ែម អេន (ញអ) ជាសាក្សីដែលបានផ្តល់ព័តមានស្តីពីអត្តសញ្ញាណដូចខាងក្រោម:
ឈ្មោះ ញ៉ែម អេន ឈ្មោះបដិវត្ត អត់មាន កើតថ្ងៃទី៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៩ នៅភូមិ ត្រពាំងមាស ឃុំត្រង៉ិល ស្រុកកំពង់លែង ខេត្ត កំពង់ឆ្នាំង សញ្ជាតិ ខ្មែរ របររកស៊ី អភិបាលរងស្រុងអន្លង់វែង ឪពុកឈ្មោះ ញ៉ែម មាស "ស"ម្តាយឈ្មោះ ហួន ជា"ស"
ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ..........ផ្លូវលេខ..........ភូមិ ថ្នល់កែងឃុំអន្លង់វែង ស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ ប្រពន្ធឈ្មោះ ស្វ ប៊ុនណារី"រ" មានកូន ១ នាក់
ទោសពីមុនមិនដែលមានទោសអ្វីទេ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, PhnomPenh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FL

D22/15

☒ ជននេះ បានប្រកាសថាខ្លួនចេះអាន សរសេរ និងយល់ ភាសា.........ខ្មែរ..........

☒ ជននេះ បានប្រកាសថាខ្លួនមិនចេះអាន និង សរសេរភាសា.........ដទៃ

ហេតុដូច្នេះ ច្បាប់ដើមនៃកំណត់ហេតុនេះ ត្រូវបានសរសេរជាភាសា............. ខ្មែរ....................

☒ យើងបានជូនព័ត៌មានរួចហើយដល់ជននេះថា ការស្តាប់យកចម្លើយនេះ នឹងត្រូវថតយកសម្លេង ឬ រូបភាព។

☒ ជននេះបានប្រាប់យើងពីទំនាក់ទំនងរបស់គេជាមួយនឹងជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីថា មិនទាក់ទង

☒ ជននេះ បានស្បថ ស្របតាមបញ្ញត្តិនៃវិធាន ២៤ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

☒ យើងបានប្រាប់ដល់ជននេះអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ស្របតាមបញ្ញត្តិនៃវិធាន ២៨ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ។

សួរ-ឆ្លើយ:

សស: សូមលោករៀបរាប់ពីប្រវត្តិរបស់លោកមុនពេលលោកមកដល់ស-២១?

ញអ: ខ្ញុំសុំជំរាបជូនថា ខ្ញុំនិយាយត្រឹមឆ្នាំ១៩៧៥ នៅថ្ងៃ១៧ មេសា ក្រោយពេលរណសិរ្សកម្ពុជា វាយលន់ ណល់ ខ្ញុំក្នុងនាមជាកុមារឈានមុនមួយ នៅស្រុកកំពង់លែង តំបន់៣១ ខ្ញុំក៏ត្រូវបានជ្រើស រើសដោយអង្គការ ដោយសារខ្ញុំជាមនុស្សខស្យាហ៍ព្យាយាមក្នុងការងារ កាលណោះអង្គការរើសតាម ឃុំ ក្នុងមួយឃុំ៧នាក់ ក្នុងនោះមានកុមារប្រហែលជាមួយពាន់នាក់ត្រូវបានអង្គការជ្រើសរើស។ ក្រោយមក អង្គការហៅមកនៅផ្ទះប្រាំជាន់ ជិតព្រលានយន្តហោះខេត្តកំពង់ឆ្នាំង កាលណោះខែ៤

ខ្ញុំមានឃើញការជម្លៀសប្រជាជនចេញពីភ្នំពេញតាមផ្លូវកំពង់ឆ្នាំងផងដែរ។

FL: លោកមានប្រសាសន៍ថាព្រលានយន្តហោះកំពង់ឆ្នាំង?

ញអ: គឺព្រលានយន្តហោះចាស់។ ខ្ញុំនៅទីនោះប្រហែលជាខែ៥ ឬ ៦ឆ្នាំ៧៥, ក្រោយមកអង្គការ បញ្ជូនខ្ញុំមកភ្នំពេញតាមរយៈឡានហ្សេអ៊ឹមសេរបស់អាមេរិកាំង ដែលកាលណោះមានឡាន១០ គ្រឿង កាលណោះតាមផ្លូវមានការដាច់ស្ពាន ដូច្នេះខ្ញុំធ្វើដំណើរអស់រយៈពេលមួយយប់ទើបមកដល់ ភ្នំពេញ។

សស: ពេលនោះលោកអាយុប៉ុន្មាន?

ញអ: កាលណោះខ្ញុំអាយុ១៦, ១៧ឆ្នាំ។ ហើយបន្ទាប់មកទៀតពេលខ្ញុំនៅភ្នំពេញ អង្គការគេបញ្ជូន ខ្ញុំមកនៅបឹងទំពន់ ទល់មុខពេទ្យរុស្ស៊ី។

សស: តើអ្នកណាជាអ្នកនាំលោកមកភ្នំពេញ?

ញអ: ខ្ញុំមិនអាចចាំបាន តែនិយាយរួមប្រហែលជាគណៈតំបន់ គណៈស្រុកកំពង់លែង ដែលគេទទួល បញ្ជាពីអង្គការមកអោយរើសកុមារល្អៗមកភ្នំពេញ។ ពេលខ្ញុំមកនៅបឹងទំពន់ខ្ញុំអត់មានធ្វើអ្វីទេ គេ អោយនៅគេងតាមផ្ទះដែលសល់ពីសង្គម ហើយបើតាមខ្ញុំស្មានខ្ញុំប្រហែលជាមកដល់ក្នុងខែ៦ ឬ ៧ ឆ្នាំ១៩៧៥។ ខ្ញុំសុំបញ្ជាក់ថា



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FC

00162835

D22115

ការរើសកុមារមកនេះ បើមិនមានការបញ្ជាពីមជ្ឈិមបក្សមកទេមិនអាច រើសបានទេ។

FL: លេខតំបន់ឈ្មោះអ្វី?

ញអ: ខ្ញុំភ្លេចឈ្មោះហើយ។ ខ្ញុំចេញពីបឹងទំពន់ហើយ អង្គការបញ្ជូនខ្ញុំទៅនៅតាខ្មៅ នៅក្រពើហារ នៅតាមដងស្ទឹងព្រែកត្នោត ហើយគេអោយខ្ញុំហាត់ខាងផ្នែកបច្ចេកទេស។

FL: នៅពេលនោះអ្នកណាជាប្រធាននៅតាខ្មៅ?

ញអ: កាលណោះ យើងមានអគ្គសេនាធិការ ខ្ញុំអត់ស្គាល់ឈ្មោះទេ តែមានឈ្មោះណាត ឈ្មោះពីន តែតាពីនជាប្រធានកងពល៧០ពាក់ខាងបច្ចេកទេស។

សស: ហាត់បច្ចេកទេសអ្វី?

ញអ: គេអោយរៀនបច្ចេកទេសយោធា គឺបច្ចេកទេសសមរភូមិគ្រប់យ៉ាងទាំងអស់ ទាំងបច្ចេកទេស ខាងកងទ័ពជើងគោក ជើងអាកាស គឺរៀនទាំងអស់។

FL: តាខ្មៅនៅពេលនោះគេហៅឈ្មោះអ្វី?

ញអ: កាលណោះនៅខាងក្រោយពេទ្យឆ្កួត នៅតាមដងស្ទឹងព្រែកត្នោត។

FL: ក្រៅពីជាកន្លែងហាត់បច្ចេកទេស តើកន្លែងនោះមានបង្រៀនអ្វីផ្សេងទេ?

ញអ: អត់មានអ្វីផ្សេងទៀតទេ តែបើកុមារដែលខ្ជិលច្រអូសនឹងការងារគេអោយទៅធ្វើស្រែ អ្នកខ្លះ គេអោយទៅតាមរោងចក្រ អ្នកខ្លះគេអោយទៅខាងកងទ័ព។ កាលណោះកុមារ ប្រហែលជា៥០-៦០ នាក់ដែលត្រូវបានគេពិនិត្យប្រវត្តិរូបថាជាកុមារឈានមុខគេ គេក៏បញ្ជូនទៅរៀននៅប្រទេស ចិន។

សស: ដូច្នេះទៅចិនទាំង៥០នាក់ ឬក៏ម្នាក់ឯង?

ញអ: ទៅចិនកាលណោះមានគ្នា៤៦នាក់ តែកាលទៅចិននោះមានការបំពាក់បំប៉នពីអង្គការដែរ គេ មានការពិនិត្យសុខភាពរួចអស់ ទើបគេបញ្ជូនខ្ញុំទៅកំពង់សោមអោយជិះនាវាទៅប្រទេសចិន។

សស: មុននឹងលោកចេញទៅចិន អ្នកណាហ្វឹកហាត់លោក?

ញអ: សុទ្ធតែខ្មែរតែម្តង អត់មានជនជាតិផ្សេងទេ។

សស: ពេលហាត់នោះគេមានប្រាប់ថាហាត់ដើម្បីធ្វើអ្វី?

ញអ: បើនិយាយធម្មតា ការបង្ហាត់យោធា សំខាន់ទិសដៅរបស់អង្គការគឺដើម្បីការពារទឹកដី ការពារ សង្គម គេមានណែនាំដែរ។

សស: ការបង្រៀនោះមានដែលប្រើពាក្យថាដើម្បីយកទៅវាយវៀតណាមទេ?

ញអ: កាលណោះអត់មាននិយាយទេ តែសំខាន់ដើម្បីពង្រឹងស្មារតី ទឹកចិត្តដើម្បីការពារបូរណភាព ទឹកដីតែម្តង។

FL: នៅពេលដែលហាត់នៅតាខ្មៅ តើគេមាននិយាយពីខ្មាំងរបស់បដិវត្តទេ?

ញអ: កាលណោះការអប់រំអត់ទាន់មានអ្វីទាំងអស់ សំខាន់គឺហាត់តែបច្ចេកទេសទឹកដី សំខាន់គឺការ ពារព្រំដែន និងប្រឆាំងនឹងចក្រពត្តិតែម្តង។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FC

FL: នៅពេលហាត់នៅតាខ្មៅ តើលោកមានដែលថ្នាក់លើទៅមើលទេ?

ញអ: ថ្នាក់លើខ្ញុំឃើញតែតាណាត និងសុន សេន។

FL: ពេលសុន សេនទៅដល់កន្លែងហាត់នៅតាខ្មៅ តើសុន សេន មាននិយាយអ្វីទេ?

ញអ: ការផ្តាំផ្ញើរបស់គាត់គឺអោយកុមារខិតខំការរៀនសូត្រពីបញ្ហាបច្ចេកទេសទាំងអស់ដើម្បីអោយក្លាយជាកុមារឈានមុខនៅពេលនោះ។

FL: លោកនិយាយពីគណៈកម្មាធិការមជ្ឈិម តើលោកដឹងតាំងពីពេលនោះ ឬក៏ក្រោយមក?

ញអ: កាលណោះមានឮតែគណៈកម្មាធិការមជ្ឈិមបក្សនៅពេលប្រជុំ។

សស: តើលោកទៅដល់ប្រទេសចិននៅពេលណា?

ញអ: ខ្ញុំមិនដឹងខែមិនដឹងថ្ងៃទេ ខ្ញុំធ្វើដំណើរតាមនាវា ហើយតាមឡាន ពេលខ្ញុំទៅដល់ចិនគេ ពិសោធន៍យើង ដូចថាគេអោយយើងគេងគ្រែតូចមួយ ដើម្បីចង់ដឹងថាកុមារល្អមិនល្អ គេអោយយើង បត់ភួយ ដើម្បីចង់ដឹងថាយើងឧស្សាហ៍ឬមិនឧស្សាហ៍ កាលណោះការបត់ភួយ ខ្ញុំទទួលបានចំណាត់ថ្នាក់ លេខមួយ និយាយរួមសីលធម៌ខ្ញុំបានលេខមួយ។ ការចាប់ផ្តើមរៀនទីមួយគឺការថតរូបធម្មតា ថតកុន បញ្ចាំងកុន គូសផែនទី និងផ្តិតរូបធម្មតា ដែលមានរយៈពេល៦ខែ។

សស: អ្នកណាជាអ្នកបង្រៀន?

ញអ: អ្នកបង្រៀនជាជនជាតិចិន តែគាត់និយាយភាសារខ្មែរ តែក៏មានការបកប្រែខ្លះដែរ

សស: រៀនរយៈពេលប៉ុន្មាន?

ញអ: រៀន៦ខែ រៀនទាំងអស់។

សស: ពេលនោះនៅប៉េកាំង?

ញអ: ខ្ញុំមិនដឹង គេគ្រាន់តែថានៅប្រទេសចិន តែខ្ញុំដឹងថាមិនមែននៅប៉េកាំងទេ។

FL: អ្នកដែលទៅរៀនថតជាមួយលោកមានប៉ុន្មាននាក់?

ញអ: កាលណោះធ្វើដំណើរទៅរួមគ្នា តែពេលទៅដល់ចិនគេបំបែកផ្នែកទាំងអស់ ខ្លះទៅខាងគីមី ខាងនាវា ខាងជីវសាស្ត្រ មានតែខ្ញុំទេទៅរៀនខាងថតរូប។

FL: អ្នកណាដែលធ្វើការបកប្រែពីខ្មែរទៅចិន ពីចិនទៅខ្មែរ?

ញអ: អ្នកបកប្រែគឺខ្មែរយើង តែជនជាតិចិននោះក៏ចេះខ្មែរខ្លះដែរ។

FL: ក្នុងចំណោមសិស្សដែលរៀនមានជនជាតិផ្សេងទេ?

ញអ: អត់មានទេ មានតែខ្ញុំម្នាក់គត់។

សស: ខាងកម្ពុជាភិបាលខ្មែរ អ្នកណាជាអ្នកនាំទៅចិន?

ញអ: តាណាតជាអ្នកជូនទៅដល់ចិនតែម្តង តែតាណាតគាត់មិនធ្វើដំណើរតាមនាវាទេ ខ្ញុំជួបគាត់នៅ ប្រទេសចិន។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។

Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FC

FL: តាណាតនោះជាអ្នកណា?

ញអ: តាណាតមកពី៧០៣។

FL: ដូច្នេះតាណាតគាត់ទៅចិនដែរ?

ញអ: បាទ! កាលណោះគាត់អគ្គសេនាធិការនាសម័យនោះបន្ទាប់ពីសុន សេន។

FL: លោកទៅដល់ស្រុកចិន គាត់នៅទីនោះស្រាប់ មានន័យថាក្នុងខែ១ ៧៦តាណាតនៅស្រុកចិន?

ញអ: បាទ! គាត់ជាមនុស្សសំខាន់មួយក្នុងការរៀបចំកងទ័ព គាត់អតីតគាត់ជាប្រធានកងពល១២។

FL: មានដឹងថាតាណាតត្រឡប់មកស្រុកខ្មែរវិញនៅពេលណា?

ញអ: ពេលមកត្រឡប់មកជាមួយខ្ញុំដែរ តែខ្ញុំអត់បានជិះយន្តហោះទេ។

សស: តើពេលតាណាតមានណែនាំអោយជួបកម្មាភិបាលចិន ឬស្ថាប័នចិនណាមួយទេ?

ញអ: អត់មានទេ សំខាន់ការណែនាំរបស់គាត់គឺអោយយើងប្រឹងរៀនសូត្រ និយាយរួមការរៀនសូត្រ កុំអោយធ្វេសប្រហែសច្រើនដង។ ខ្ញុំជួបឯកអគ្គរាជទូតចិននៅស្រុកខ្មែរម្តងនៅស្រុកចិន គាត់ឈ្មោះ ស៊ុន ហាវ។

សស: ស៊ុន ហាវ ជួបលោកក្នុងន័យអ្វី?

ញអ: គាត់ជួបនៅឆ្នាំ៧៦ គាត់មកជួបដើម្បីសរសើរកុមារឈានមុខនិងកុមារល្អ កាលណោះគេ អោយមេដៃខ្ញុំមួយមានរូបប្រធានម៉ៅនៅកណ្តាល តែខ្ញុំបាត់អស់ហើយ។

FL: នៅពេលណាលោកត្រឡប់មកស្រុកខ្មែរវិញ?

ញអ: ខ្ញុំមកដល់ភ្នំពេញអត់ទាន់បានចូលធ្វើការនៅស-២១ទេ ខ្ញុំនៅមន្ទីរអគ្គសេនាធិការភ្នំពេញ គឺ ខ្ញុំដើរថត ខ្ញុំមកដល់អាចនៅចុងឆ្នាំ៧៦ ឬក៏ដើមឆ្នាំ៧៧។

សស: ពេលដែលស៊ុន ហាវ មកមើលលោករៀន តើមានកម្មាភិបាលខ្មែរយើងមកដែរ?

ញអ: មានគណៈប្រតិភូខ្មែរយើងមកច្រើនដែរ ខ្ញុំអត់ចាំទេ តែខ្ញុំមានរូបថតដែរ។

FL: លោកមានប្រសាសន៍ពីរូបថតកាលជំនាន់នោះ តើលោកអាចអោយខ្ញុំមើលបានទេ?

ញអ: ខ្ញុំអត់បានយកមកទេ តែខ្ញុំយកសៀវភៅដែលខ្ញុំទៅរៀននៅចិន និងរូបថតខ្ញុំទៅរៀននៅចិន។

FL: តើឯកសារអស់នេះលោកអាចផ្តល់អោយយើងថតចម្លងបានទេ?

ញអ: បើតុលាការត្រូវការខ្ញុំមិនបដិសេធទេ តែចាំខ្ញុំយកទៅធ្វើអោយ។

សស: លោកថាមានសល់រូបថតពេលគណៈប្រតិភូទៅជួបលោកនៅចិន?

ញអ: អត់មានទេ ខ្ញុំមានតែរូបថតតាណាត ខ្ញុំមានរូបថត២០០០សន្លឹក។

សស: តើលោកធ្វើអ្វីពេលលោកមកដល់ស្រុកខ្មែរ?

ញអ: ខ្ញុំមកនៅអគ្គសេនាធិការភ្នំពេញ នៅពេទ្យមុន្នីវង្ស។

FL: នៅពេលនោះពេទ្យមុន្នីវង្សគេប្រើជាអ្វី?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

D22/15

ញអ: ពេលនោះគេហៅពេទ្យព-៩៨ ជាពេទ្យរបស់អគ្គសេនាធិការកងទ័ព។

FL: តើលោកធ្វើអ្វីនៅពេទ្យនោះ?

ញអ: ខ្ញុំមិនមែននៅពេទ្យទេ តែនៅជិតកន្លែងនោះ។

FL: តើលោកធ្វើអ្វីនៅជិតពេទ្យនោះ?

ញអ: កាលនោះចាប់ផ្តើមធ្វើកន្លែងរោងពុម្ពដែល ធ្វើកាសែត ទស្សនាវដ្តី។

FL: តើអ្នកណាប្រធានលោកកាលណោះ?

ញអ: ប្រធានខ្ញុំមានពីរនាក់ ម្នាក់នោះឈ្មោះតាប៉ង់ គាត់គឺជាភ្នាក់ងារពិសេសរបស់ប៉ុល ពត ហើយ ម្នាក់ទៀតឈ្មោះនឿន គាត់នៅជាប់ជាមួយសុន សេនដែរ តែខ្ញុំមិនដឹងគាត់ទៅណាអស់ហើយសព្វថ្ងៃ នេះ។

FL: តើនឿនតួនាទីជាអ្វី?

ញអ: តាមពាក្យអង្គការ គេហៅថានិរសាក្រុង។

FL: តើការងារនិរសាក្រុងធ្វើអ្វី?

ញអ: បើប្រៀបទៅដូចហ៊ីង ប៊ុនហៀងប្រធានអង្គរក្ស ហ៊ុន សែនសព្វថ្ងៃនេះ។

សស: ប៉ង់ជានិរសាក្រុងដូចនឿនដែរ?

ញអ: ពួកនោះជាអ្នកពិសេសរបស់អង្គការហើយ តែប៉ងកាលណោះមានតួនាទីធំជាងនឿន ប៉ង់នោះ ហើយជួយអោយខ្ញុំរស់ដល់សព្វថ្ងៃនេះ កាលនោះខែកញ្ញា ឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាប្រកាស ថា ជាបក្សកុម្មុយនីស្តពេញសិទ្ធិនៅលើពិភពលោក។

FL: តើលោកធ្វើអ្វីកាលនោះ?

ញអ: ការងារខ្ញុំគឺថតពេលប្រជុំថ្នាក់ដឹកនាំ ប្រជុំសភា ប្រជុំកងទ័ព និងពេលមានគណៈប្រតិភូ បរទេសមកគឺខ្ញុំជាអ្នកថត។

FL: តើលោកមានដែលចេញទៅក្រៅភ្នំពេញដើម្បីថតរូបទេ?

ញអ: ខ្ញុំទៅថតតាមភូមិភាគដែរ ខ្ញុំច្រើនទៅភូមិភាគនិរតី ពាយ័ព្យ ឧត្តរ និងបស្ចឹម។

FL: តើលោកទៅថតរូបប្រភេទណា? ហើយលោកឃើញអ្វីខ្លះ?

ញអ: ខ្ញុំថតពេលថ្នាក់ដឹកនាំចុះទៅមើលការលើកទំនប់ ប្រឡាយ តើការងារជឿនលឿន ឬមិនជឿន លឿន។

FL: អ្នកដឹកនាំដែលលោកចុះទៅនោះមានអ្នកណា?

ញអ: ជួនកាលមានអ៊ំប៉ុល ពត, នួន ជា, សុន សេន ជួនកាលមាន ខៀវ សំផន ហើយជួនកាលមាន ជួបជាមួយគណៈភូមិភាគដូចជាតាម៉ុក។

FL: ពេលលោកជួបជាមួយនួន ជា តើលោកទៅថតនៅខេត្តណា?

ញអ: រូបថតខ្ញុំថតនួន ជា គឺពេលគាត់ទៅមើលប្រឡាយ ទំនប់ នៅភូមិភាគបស្ចឹម ប្រហែលជាឆ្នាំ ១៩៧៧។

FL: ចុះខៀវ សំផន ទៅកន្លែងណាដែរ?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FC

ញអ: គាត់មិនសូវទៅតាមជនបទទេ ព្រោះគាត់ធ្វើការខាងគណៈប្រតិភូរដ្ឋ ខ្ញុំកម្រឃើញគាត់ទៅ តាមជនបទណាស់។

សស: ដូច្នេះលោកធ្លាប់ថតខៀវ សំផនៅភ្នំពេញ?

ញអ: ខ្ញុំថតគាត់ពីរដង នៅបុរីកីឡាម្តង និងសាលចតុមុខនេះម្តង។

សស: ថតនៅបុរីកីឡា តើថតឆ្នាំណា? ក្នុងពិធីអ្វីដែរ?

ញអ: ដូចជាក្នុងពីធី១៧ មេសា ឬបុណ្យខួបបក្សជាដើម។

FL: មានដែលជួបលោកខៀវ សំផនទៅខេត្ត ហើយថតគាត់ទេ?

ញអ: មានដែរ ខ្ញុំថតថ្នាក់ដឹកនាំទូទាំងប្រទេសទៅហើយ វាច្រើនពេក។

FL: តើលោកមានចាំថានៅខេត្តណាមួយទេ?

ញអ: កាលនោះមានការប្រជុំពិសេសមួយនៅកោះធំ មានរូបថតមួយដែលខៀវ សំផនកំពុងឈរ និង រូបអៀង សារីអង្គុយ ហើយមានម៉ាស៊ីនថតគុននៅខាងក្រោយ។

សស: តើក្នុងពិធីអ្វីដែរនៅកោះធំនោះ?

ញអ: នៅសហករណ៍ នៅឆ្នាំ៧៧ ដើម៧៨ កាលណោះខ្ញុំធ្វើការទួលស្លែងផង តែពេលខ្ញុំថតនៅទួល ស្លែង ផុតពីការងារទំនេរ គេអញ្ជើញខ្ញុំទៅ ដូចជាមានគណៈប្រតិភូចិនមក។

សស: ពេលថតនៅបុរីកីឡា តើថតនៅឆ្នាំណា?

ញអ: ឆ្នាំ៧៧។

សស: ចុះនៅចតុមុខក្នុងពិធីអ្វី? ហើយនៅឆ្នាំណា?

ញអ: កាលណោះជាពិធីប្រកាសគណៈប្រធានរដ្ឋយ៉ាងម៉េចមិនដឹងទេ ខ្ញុំភ្លេចហើយ។ រឿងឆ្នាំនោះខ្ញុំ ភ្លេចហើយ។

សស: ក្រៅពីថ្នាក់ធំៗ តើលោកមានថតនរណាទៀតទេ ដូចជាអៀង សារី អៀង ធីរិទ្ធ?

ញអ: មាន មានច្រើន បើខ្ញុំឃើញរូបថតខ្ញុំស្គាល់ ទោះខ្ញុំមិនចាំអស់ក៏ខ្ញុំស្គាល់ដែរ។

FL: ឧទាហរណ៍ដូចជាអៀង សារី តើលោកមានដែលថតរូបគាត់ពេលប្រជុំ ឬទៅតាមខេត្តណាមួយ ទេ?

ញអ: អៀង សារីភាគច្រើនពេលនៅជាមួយប្រតិភូបរទេស តែអ្នកថតមានផ្សេងគ្នា អ្នកនៅខាង អគ្គសេនាធិការផ្សេង ហើយនៅខាងអៀង សារីមានអ្នកថតរូបគេផ្សេង តែពេលផ្តិត ពេលខ្លះខ្ញុំ គឺជាអ្នកផ្តិត ការងារខ្លះគេមិនអោយយើងដឹងទេ។

FL: ដូច្នេះការងារលោកគឺអ្នកផ្តិតរូបនៅជិតមន្ទីរពេទ្យឃោធា?

ញអ: បាទ!

FL: លោកមានចាំទេ អ្នកណាអ្នកថតរូបអៀង សារី?

ញអ: ខ្ញុំមិនចាំទេ ខ្ញុំនៅក្នុងមន្ទីរ៦២ក គឺនៅជាប់ជាមួយអង្គការតែម្តង វាជាផ្នែកនៃ មន្ទីរ៨៧០ធំ ជាងគេ ហើយគេមានបែងចែកជាមន្ទីរផ្សេងៗទៀត។

FL: មានដឹងអ្នកណានៅ៨៧០ អ្នកណាជាអ្នកប្រធាន?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FL

ញអ: បើនិយាយរួមតាប៉ុល ពតនោះជាប្រធាន ហើយមន្ទីរ៨៧០ធំជាងគេនៅស្រុកខ្មែរ។

សស: លោកធ្លាប់ថតរូបរបស់អៀង សារីផ្ទាល់ ឬក៏ផ្តិតរូបគាត់?

ញអ: ខ្ញុំភាគច្រើនផ្តិតរូបរបស់គាត់។

សស: ចុះអៀង ធីរិទ្ធ?

ញអ: ខ្ញុំធ្លាប់ផ្តិតដែរ ដែលខ្ញុំស្គាល់មុខច្បាស់មានតែសុន សេន, ប៉ុល ពត ខៀវ សំផន នួន ជា, តែប្រពន្ធៗគេខ្ញុំមិនអាចដឹងបានអស់ទេ វាច្រើនពេក។

សស: ដូច្នេះអ្នកថតជាមួយលោកមានប៉ុន្មាននាក់?

ញអ: មាន៦នាក់ ៦នាក់នោះមានម៉ាស៊ីន៦ អ្នកណាថតអ្នកនោះផ្តិត និងលាង អ្នកថតមាននាទីខុសគ្នា ទាំងអស់។

សស: សូមរៀបរាប់ពីឈ្មោះអ្នកដែលថតជាមួយលោក?

ញអ: ពេលនៅជិតពេទ្យមុន្នីវង្សនោះមានតែខ្ញុំម្នាក់ឯង។

FL: ពេលណាលោកទៅស-២១?

ញអ: ខ្ញុំមិនចាំថ្ងៃដែរ តែក្នុងដើមឆ្នាំ៧៧។

FL: អ្នកណាចាត់តាំងលោកទៅ?

ញអ: កាលនោះមានសុន សេន មានតាណាត ព្រោះកាលខ្ញុំទៅចិនក៏មានតាណាត និងសុន សេន ដែរ ហើយការងារក៏គាត់អ្នកចាត់អោយធ្វើដែរ។

FL: លោកមានបានដឹងទេ ហេតុអ្វីគេអោយលោកទៅធ្វើនៅស-២១?

ញអ: ខ្ញុំអត់ដឹងដែរ ព្រោះជាការងាររបស់អង្គការ ការងារថតរូបនៅស-២១គឺមានពីរផ្នែក ទីមួយគឺ ថតអ្នកទោសនៅស-២១ ទី២ពេលទំនេរខ្ញុំទៅថតនៅខាងក្រៅ។

សស: ពេលនៅជិតពេទ្យមុន្នីវង្ស តើក្រៅពីប៉ង និងនឿន តើនរណាផ្សេងទៀត?

ញអ: អត់មានទេ ខ្ញុំតែម្នាក់ឯង។

សស: លោកនៅជិតពេទ្យមុន្នីវង្សប៉ុន្មានឆ្នាំដែរ ទើបទៅស-២១?

ញអ: ខ្ញុំមិនចាំទេ តែដឹងថានៅដើមឆ្នាំ៧៧ខ្ញុំចូលទៅស-២១តែម្តង។

FL: លោកធ្វើការប៉ុន្មានខែពេលនៅជិតពេទ្យមុន្នីវង្ស?

ញអ: ប្រហែលជា៣-៤ខែប៉ុណ្ណោះ ព្រោះធ្លាក់ខ្យល់ហើយ ប្រហែលជាខែ១១, ១២ហ្នឹង។

សស: ពេលលោកមកស-២១ តើលោកនៅក្រោមការដឹកនាំរបស់អ្នកណា? ហើយនៅអាគារណា?

ញអ: ខ្ញុំនៅផ្ទះថ្ម សព្វថ្ងៃជាស្ថានទូតហុងគ្រី នៅទល់មុខក្រសួងផែនការ។

FL: អ្នកណាដែលនៅផ្ទះជាមួយលោក?

ញអ: នៅរួមគ្នា៦នាក់ ជាងថតរូបទាំងអស់។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

D22/15

FL: សូមលោករៀបរាប់ពីការងារប្រចាំថ្ងៃនៅស-២១?

ញអ: គេមានគោលការណ៍របស់គេ ព្រឹកឡើងម៉ោង៦:៣០យើងមកដល់កន្លែងបាយរួម ហូបបបរ ហើយម៉ោង៧យើងចូលធ្វើការ យើងថតអ្នកទោសដែលមកដល់ ហើយសម្រាកម៉ោង១១ ហើយ ម៉ោង៥ចេញ តែក្រោយពីនោះអត់មានធ្វើអ្វីទេ យើងណ្តាតដាំស្លៃសម្រាប់ខ្លួនឯង។

FL: លោកនិយាយថា ការងារស្នូលចាប់ផ្តើមពីម៉ោង៧ តើធ្វើអំពីអ្វី?

ញអ: យើងថតរូបអ្នកទោស ពេលត្រឡប់មកវិញ យើងលាងហ្វីល និងផ្តិតខ្លួនឯង។

FL: តើអ្នកទោសមកដល់ពេលណា?

ញអ: អត់ទៀង តែអ្នកថត៦នាក់គឺចែកវេណគ្នាថត។

FL: នៅពេលនោះតើអ្នកទោសមកស-២១រាល់ថ្ងៃ?

ញអ: បើនិយាយពីអ្នកទោសគឺមករាល់ថ្ងៃ គ្រាន់តែតិចនិងច្រើនប៉ុណ្ណោះ។

FL: លោកនិយាយថា ក្រុមលោកមាន៦នាក់ តើអ្នកណាប្រធាន? ហើយឋានៈលោកអ្វីដែរ?

ញអ: កាលណោះស្រ៊ាងប្រធានក្រុម ហើយខ្ញុំជាប្រធានពួក ស្រ៊ាងគេក្តាប់ពីរនាក់ ហើយ ខ្ញុំក្តាប់ពីរនាក់ទាំងអស់មាន៦នាក់ តែស្រ៊ាងប្រធានធំជាងគេ។

FL: លោកទទួលបញ្ជាពីអ្នកណា?

ញអ: កាលណោះមានសុន សេន, តាណាត កាលណោះក៏មានឌុចដែរ គាត់ប្រធានស-២១។

FL: អ្នកដែលបញ្ជាលោកផ្ទាល់ជាអ្នកណា?

ញអ: ឌុចអ្នកបញ្ជាផ្ទាល់ ហើយគាត់មើលការខុសត្រូវទាំងអស់នៅក្នុងនោះ។

FL: តើលោកមានចាំបញ្ជារបស់ឌុចចំពោះលោកទេ?

ញអ: ការបញ្ជារបស់គាត់គឺហ្មឹងម៉ាត់តែម្តង បើខ្ញុំធ្វើខុសអ្វីមួយគឺមិនបាន។

FL: លោកបានឮឌុចប្រើពាក្យអស់នេះ?

ញអ: បាទ!

FL: លោកនិយាយថា តែឌុចបញ្ជាអោយធ្វើអ្វីគឺត្រូវធ្វើអោយបាន បើសិនជាខុសលោកថាមានបញ្ហា តើបញ្ហានោះយ៉ាងម៉េច?

ញអ: បញ្ហានោះគឺបញ្ហាអាយុជីវិតតែម្តង ព្រោះជាចំបងអាយុជីវិតទីមួយ ហើយទី២ការងារគឺប្រុង ប្រយ័ត្នជាទីបំផុត មិនអោយខូចដាច់ខាត។

FL: ឌុចបញ្ជាមកលោកហាក់ដូចជាការគំរាមកំហែង?

ញអ: វាគឺជាការពិត ព្រោះការងារនៅស-២១ អ្នកដែលមកតាំងពី៧៥ មកពីកំពង់ឆ្នាំងនោះ បានបាត់បង់ជីវិតនៅស-២១នោះច្រើនណាស់ ភាគច្រើនអ្នកយាមដែលយាមងោកនោះគេយក ទៅវៃចោល ដូចជាចន ហើយមួយទៀត ស្រ៊ុន នោះមកជាមួយខ្ញុំដែរ ពេលគាត់យកស្លៃដែល ស្រោចអង់ទ្រីន ហើយលាងមិនជ្រះ ពេលគាត់យកទៅស្លលាងអត់ជ្រះវាធំក្លិន



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FL

00162842

D22/115

គេចោទថាគាត់ដាក់ ថ្នាំបំពុល ហើយគេយកទៅវ៉ៃចោលទាំងអស់។

FL: តាមលោកយល់ អ្នកណាដែរទទួលខុសត្រូវចំពោះការស្លាប់របស់អ្នកទាំងនោះ?

ញអ: និយាយអោយខ្លីគឺតាឌុច ព្រោះនៅស-២១មិត្តភ័ក្តខ្ញុំដែលមកពីស្រុកភូមិជាមួយខ្ញុំនោះបាត់ ច្រើនណាស់។

FL: លោកសំអាងទៅលើអ្វីដែលថាឌុចជាអ្នកទទួលខុសត្រូវ?

ញអ: តាមដែលខ្ញុំដឹង ព្រោះវាជាបទបញ្ជារបស់គាត់តែម្តង ព្រោះអ្នកស-២១មានការបាត់ច្រើន ណាស់ ក្នុងនោះប្រហែលជា៤០០នាក់ មានបាត់អស់១៥០នាក់ហើយ។

សស: តើឌុចមានណែនាំពីការថតដល់លោកទេ?

ញអ: អត់ទេ សំខាន់ការណែនាំរបស់គាត់គឺថាកុំអោយខូច ពេលយើងថតហើយត្រូវបញ្ជូនទៅអោយ ធី តែការធ្វើនោះកម្រខូចណាស់ព្រោះខ្ញុំប្រយ័ត្នជាទីបំផុង។

សស: ពេលដែលលាងហ្វីលនោះ តើលោកលាងនៅឯណា?

ញអ: ខ្ញុំយកទៅលាងនៅមុខក្រសួងផែនការ។

សស: សូមលោករៀបរាប់ពីការថត ចាប់តាំងពីការនាំអ្នកទោសចូលមក ហើយការដាក់ផ្លាកចំណាំ អ្នកទោស?

ញអ: ដូចថាគេដឹកឡានមក ពេលនោះអ្នកទោសគេចងមុខ ហើយអ្នកនាំយកមកអោយយើងគេ ស្រាយមុខ។

សស: អ្នកណាដែលស្រាយមុខនោះនរណាគេ?

ញអ: អ្នកយាមគេអ្នកស្រាយមុខ។

FL: កន្លែងថតនៅកន្លែងណា?

ញអ: នៅទល់មុខផ្លូវចូលទួលស្លែងសព្វថ្ងៃ នៅខាងក្រៅរបងទួលស្លែង តែកន្លែងលាងហ្វីលនៅជិត ផ្ទះតាឌុច។ ថតអ្នកទោសមុនបញ្ចូលទៅចូលគុក។

FL: តើលោកមានដឹងថាអ្នកទោសគេបញ្ជូនមកពីណាទេ?

ញអ: អត់ដឹងទេ។

FL: ឡានដែលដឹកមកនោះ តើជាឡានរបស់ស-២១?

ញអ: យើងពិបាកពិព័ណ៌ដែរ ឡានគេមានដាក់ឡានភូមិភាគបស្ចឹម ពាយ័ព្យ យើងអត់ដឹង ជួនកាល គេអត់ដាក់ផ្លាក ជួនកាលគេដឹកតាមឡានតូច ឡានរបស់ស-២១ក៏មានដែរ។

FL: និយាយពីឡានរបស់ស-២១ ក្នុងពេលឡានចេញទៅយកអ្នកទោស តើអ្នកណាចេញទៅយក អ្នកទោស?

ញអ: យើងមិនអាចដឹងបានទេ គេមានផ្នែក១ផ្សេងគ្នា វាច្រើនណាស់ តែខ្ញុំអ្នកថតគឺដឹងតែថត។

FL: មានដែលឃើញឌុចនៅក្នុងឡានដែលគេនាំអ្នកទោសមកទេ?

ញអ: យើងមិនបានសង្កេតមើលដែរ។

សស: ពេលថត តើគេមានដាក់ឈ្មោះអោយអ្នកទោសដើម្បីអោយធីស្រួលចំណាំទេ?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FL

D22/15

ញអៈ យើងចង់និយាយថា ពេលថតគេមានលេខចំណាំគេ ជួនកាលគេដាក់ឈ្មោះ ជួនកាលគេមាន លេខ ជួនកាលក៏អត់មានដាក់លេខដែរ ហើយលេខរបស់អ្នកទោសគឺផ្លាស់ប្តូរតាមថ្ងៃ ហើយថ្ងៃក្រោយមកទៀតគឺចាប់ផ្តើមលេខថ្មីឡើងវិញ។

សសៈ តើមានអ្នកជួយរៀបចំផ្ទាក រៀបចំឯកសារទេ?

ញអៈ ជួនកាលខ្ញុំរៀបចំខ្លួនឯង អត់មានអ្នកជួយទេ។

សសៈ តើលោកចំណាំរបៀបម៉េច?

ញអៈ អត់មានអ្វីពិបាកទេ ដូចថាអ្នកទោសចូល១០០អ្នក រូបថត១០០សន្លឹកដែរ ដាក់តែលេខ ដូចថា ឈ្មោះកលេខ១ ឈ្មោះខលេខ២។

សសៈ បានន័យថា អ្នកនាំមកអត់មានអោយបញ្ជីមកលោកទេ?

ញអៈ អត់មានអោយទេ អោយទៅធីតែម្តង។

FL: អ្នកទោសដែលនាំមកទាំងអស់ត្រូវថតរូបទាំងអស់?

ញអៈ ភាគច្រើនថត មានតិចទេដែលអត់បានថត។

FL: ហេតុអ្វីបានអត់ថត?

ញអៈ ជួនកាលយើងដល់យប់ជ្រៅយើងអត់បានថត ជួនកាលគេអោយយើងថតដល់បន្ទប់ តែកម្រ ណាស់ អ្នកទោសត្រូវតែថតរូបទាំងអស់។

FL: តើក្រៅពីថតអ្នកទោស លោកមានដែលថតក្នុងបរិវេណគុកស-២១ទេ?

ញអៈ បរិវេណគុកគេមិនអោយខ្ញុំចូលទេ។

FL: មានដែលធ្លាប់ថតរូបអ្នកទោសក្រោយពីគេសម្លាប់ហើយទេ?

ញអៈ ខ្ញុំអត់ដែលទេ តែគេមានក្រុមពិសេសគេមួយទៀត គឺឈ្មោះស្រ៊ុ គាត់នោះនៅកងការពារ ពិសេស ពេលមានអ្នកស្លាប់គាត់គឺជាអ្នកថត។

FL: តើការថតរូបអ្នកស្លាប់ហើយញឹកញាប់ទេ?

ញអៈ មានញឹកញាប់ដែរ ពេលគេថតហើយគេអោយយើងផ្តិតតែមិនអោយប្រាប់អ្នកផ្សេងទេ។

FL: តើហេតុអ្វីបានគេថតរូបអ្នកដែលស្លាប់ហើយ?

ញអៈ បើតាមខ្ញុំដឹងប្រហែលគ្រាន់តែជាការកត់សំគាល់ តែស្រ៊ុនោះប្រហែលជាស្លាប់ហើយ តាឌុចជា អ្នកសម្លាប់ ខ្ញុំដឹងថាស្រុកកំណើតគាត់នៅស្រុកបាទី ខេត្តតាកែវ មិនដឹងភូមិឃុំទេ។

FL: អ្នកណាបញ្ជាអោយថតអ្នកដែលស្លាប់ហើយ?

ញអៈ មានតែឌុចទេ។

FL: ហេតុអ្វីលោកសន្និដ្ឋានដូច្នេះ?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FC

D22/115

ញអ: អ្នកស្លាប់នោះប្រហែលជាសួរចម្លើយមិនទាន់អស់ ហើយទីពីរគឺការធ្វើទារុណកម្ម ព្រោះរូបថត មានបែកឈាមមានអី។

FL: តើលោកដឹងថាអ្នកណាបញ្ជាឌុច?

ញអ: បើតាមខ្ញុំទៅប្រជុំពីមាគ៌ារបស់អង្គការគឺសុន សេនជាចំបង អានេះតាមដែលខ្ញុំឃើញនឹងភ្នែក ឬតាមគាត់មកប្រជុំសន្និបាតនៅស-២១ ក្រៅពីសុន សេន អត់មានឃើញនរណាមកទេ។

FL: ការទាក់ទងឌុច និងសុន សេន តើឌុចសុំបញ្ជាពីសុន សេន ឬសុន សេនចេញបញ្ជាមកឌុច?

ញអ: ការសម្រេចរបស់ឌុចគឺរឿងមួយ ហើយការបញ្ជាពីសុន សេន គឺជាចរន្តតែម្តង បើសរុបមក ទាំងពីរនាក់នោះគឺស្មើរគ្នាតែម្តង បើឌុចមិនរាយការណ៍ទេ សុន សេន, ប៉ុល ពត, នួន ជាក៏មិនដឹង ឯកសារទាំងអស់គឺនៅលើឌុច ឌុចគឺសំខាន់ណាស់ ឌុចគឺជាអ្នកកំណត់ឈ្មោះអ្នកដែលត្រូវសម្លាប់ គាត់ជាអ្នកអោយភ្លើងខៀវទៅអោយសុន សេន និងប៉ុល ពត។

សស: អ្នកទោសសំខាន់ណាខ្លះដែលលោកបានថត ដូចជាកុយ ធួន, ហ៊ូ នឹម?

ញអ: ខ្ញុំមិនបានថតទេ គឺស្រ៊ីជាអ្នកថត គុកពិសេសគឺផ្ទះថ្មនៅខាងក្រៅស-២១នោះសម្រាប់ដាក់អ្នក ទោសថ្នាក់តំបន់ ខ្ញុំមិនដែលបានចូលទេ។

FL: តើនួន ជា មានតួនាទីអ្វី?

ញអ: គាត់ជាប្រធានរដ្ឋសភា តែមិនមែនថាគាត់មិនដឹងទេ គាត់ដឹងព្រោះការចាប់ចងថ្នាក់ភូមិភាគ តំបន់ សុទ្ធតែអ្នកសំខាន់ៗនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

FL: តើតួនាទីសន្តិសុខក្រៅពីសុន សេន តើនួន ជាយ៉ាងម៉េច?

ញអ: ខ្ញុំមិនដឹងទេ តែបើសុន សេន ក្នុងមួយអាទិត្យគាត់មកស-២១ម្តង។

FL: លោកមានដែលឮគេនិយាយពីនួន ជាថាគាត់មានតួនាទីនៅស-២១ទេ?

ញអ: ខ្ញុំឮពាក្យតាឌុចនិយាយថា បញ្ជូនទៅអោយបងទី១ ទី២ ហើយខ្ញុំដឹងថា បងទីមួយប៉ុល ពត បងទីពីរ នួន ជា។ ស-២១គឺជាមន្ទីរសន្តិសុខសំខាន់នៅក្នុងជាតិ សុន សេន និយាយពេលប្រជុំជាមួយ ឌុចថា ស-២១គឺជាដួងព្រលឹងសំខាន់របស់ជាតិ។ នួន ជា ប៉ុល ពត មិនដែលឃើញមកទេ តែបើ សុន សេន ឃើញមកជាអចិន្ត្រៃយ៍តែម្តង។

FL: លោកនិយាយថា នៅស-២១ក្រៅពីឌុចមានសុន សេន ហើយសុន សេនមកស-២១ស្ទើរាល់ អាទិត្យ តើសុន សេនមករហូតដល់៧៩?

ញអ: សុន សេនគាត់មកនោះគឺរហូតដល់វៀតណាមចូលតែម្តង តាមខ្ញុំដឹងនៅស-២១ ឆ្នាំ៧៨ ខ្សោយអ្នកទោសហើយ ចូលតែម្នាក់ពីរនាក់ទេ តែបើឆ្នាំ៧៧គឺច្រើនតែម្តង ជួនកាល២៤ម៉ោងតែ ម្តង។

សស: លោកដែលថតជនជាតិអ្វីផ្សេងក្រៅពីខ្មែរទេ?

ញអ: ខ្ញុំបានថតម្តង ជនជាតិពីរនាក់មកពីសមុទ្រ តែមិនមែនវៀតណាមទេ តែខ្ញុំមិនដឹងជាបារាំង អាមេរិកទេ។

សស: តើពីរនាក់នោះសក់ព៌ណអ្វី?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ញអ: ខ្ញុំគ្រាន់តែដឹងថាមាឌធំ ច្រមុះស្រួច សក់ពណ៌ទង់ដែង។

សស: ពេលថតហើយគេយកទៅណា?

ញអ: គាត់មានរោមច្រើន ហើយមានពុកមាត់ តែខ្ញុំមិនដឹងគេយកទៅណាទេ កាលណោះក្នុង ឆ្នាំ៧៧។

សស: មានចាំឈ្មោះទេ?

ញអ: អត់បានចាំផង។

សស: លោកមានចាំឈ្មោះអ្នកថតផ្សេងៗនៅស-២១ទេ?

ញអ: ១. ស្រ៊ាង, ២. សុង, ៣. នីត, ៤. សំ, ៥. រី, ៦គឺខ្ញុំ។

សស: ដឹងថានៅរស់ទេ?

ញអ: ខ្ញុំដឹងថាស្លាប់បីហើយ រី, សំ និងសុង ស្លាប់ហើយ តែពីរនាក់ទៀតខ្ញុំមិនដឹងដែរ។

សស: តែនីតនៅរស់ទេ?

ញអ: នៅរស់ពេលវៀតណាមចូល បីនាក់នោះស្លាប់ក្រោយវៀតណាមចូលទេ។

សស: លោកមានដែលថតចំជនជាតិចិន ឬវៀតណាមទេ?

ញអ: មានដូចជាជនជាតិវៀតណាម ព្រោះកាលណោះវៀតណាមវ៉ៃចូលកម្ពុជាតាមព្រំដែន ខ្ញុំសោក ស្តាយដែរ ខ្ញុំបាត់កាស្សែតវីដេអូអស់ហើយពីរឿងវៀតណាម ហើយអ្នកបកប្រែវៀតណាមគឺម៉ម ណៃ នៅម៉ាឡៃ។

សស: តើទាហានវៀតណាមនោះមកទាំងខោអាវ?

ញអ: បាទ!

សស: ចុះគិតវិញលោកមើលដឹងយ៉ាងម៉េចដឹងថាវៀតណាម?

ញអ: ចុះបើនិយាយវៀតណាម។

សស: មានការលើកឡើងថា ខ្មែរក្រហមពាក់ខោអាវទាហានវៀតណាមអោយ តើលោកយល់ថា មានទេ?

ញអ: អត់មានទេ ព្រោះខ្មែរក្រហមអត់មានក្រឡៃទេ ខ្មែរក្រហមចង់ធ្វើអ្វីដែលពិត។

សស: លោកថាមានវីដេអូទាហានវៀតណាម តើវីដេអូអ្វី?

ញអ: ទាហានវៀតណាមដែលខ្ញុំចាប់បាននៅសៀមរាបក្រោយ៧៩។

សស: ទាហានវៀតណាមដែលលោកថតនោះច្រើនទេ?

ញអ: ប្រហែលជា២០នាក់។

FL: នៅពេលថតរូប តើឌុចមានដែលមកមើលលោកពេលថតរូបទេ?

ញអ: មានមក តែកម្រណាស់ តែពេលញុំាបាយរួមជុំគ្នាមានគាត់មក។

FL: ពេលឌុចមក គាត់មានដែលនិយាយអ្វីជាមួយលោកទេ?

ញអ: ការនិយាយគឺថា អោយប្រុងប្រយ័ត្ន កុំអោយខូចបាត់បង់ ព្រោះរូបថតសំខាន់ណាស់សម្រាប់ ធ្វើប្រវត្តិរូប



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FL

00162846

D22115

សម្រាប់អត្តសញ្ញាប័ណ្ណ។

FL: មានបញ្ហាអ្វីទេនៅពេលរូបថតនោះថតខូច ឬមិនច្បាស់ តើលោកធ្លាប់ដែលមានបញ្ហានេះទេ?

ញអ: បើមានការខូចរូបថត គឺអត់រួចទេ គឺស្លាប់ តែពេលខ្លះរូបថតខ្ញុំថតទៅបិទភ្នែក បើមានបិទ ភ្នែក ខ្ញុំត្រូវថតម្តងទៀត។

សស: ឧបមាថា រូបថតនោះខូច តើអ្នកណាជាអ្នកសម្រេចចាប់?

ញអ: តាឌុច តាហ៊ី និងតាចាន់ ម៉ម ណៃនោះ។

FL: តើអះអាងលើអ្វីដែលលោកនិយាយដូច្នេះ?

ញអ: អានេះគឺការពិត ការសម្រេចគឺបីនាក់នោះជាអ្នកសម្រេច។ រឿងខ្ញុំមួយ ខ្ញុំផ្តិតរូបអ៊ំប៉ុល ពត ខូច ហ្វីលនោះខូចចំភ្នែក ខ្ញុំហើយនិងរីក៏ដឹងរឿងនោះដែរ ពេលនោះតាហ៊ី តាចាន់ តាឌុច Telephone មកខ្ញុំ ពួកខ្ញុំថតរូបក៏ប្រជុំគ្នា ហើយខ្ញុំរាយការណ៍ថា ខ្ញុំផ្តិតរូបអ៊ំទីមួយខូច បើមិន ជឿសួររីទៅ ពេលនោះរីថាមិនដឹងមិត្តអេនផ្តិតពីពេលណាមកទេ ពេលនោះគេដកខ្ញុំទៅចិញ្ចឹមទន្សាយ ពេលនោះអេនដែលជានិរសាររបស់ឌុចប្រាប់ខ្ញុំថា ឌុចសួរប៉ង់នាំពីរឿងនោះ ហើយប៉ង់ ថាហ្វីលនោះមានខូចមួយសន្លឹក ក្រោយមកទើបគេអោយខ្ញុំមកវិញ។

សស: តើអេននោះនៅរស់ទេ?

ញអ: ខ្ញុំមិនដឹងថាអេននៅរស់ឬក៏ស្លាប់ទេ។

សស: ស្រុកកំណើតគាត់នៅកំពង់ឆ្នាំងដែរ?

ញអ: ពួកនោះមានតែពីរទេ បើមិននៅកំពង់ឆ្នាំងទេ កំពង់ស្ពឺ។

សស: អេននោះលោកឃើញនៅរស់ពេលវៀតណាមចូល?

ញអ: បាទ!

សស: លោកថាទៅថតវិញម្តងទៀត តើថតនៅឯណា?

ញអ: អត់ទេ ថតវិញភ្លាម ព្រោះខ្ញុំដឹងថា បិទភ្នែក។

សស: លោកមានដែលទៅថតនៅព្រៃសទេ?

ញអ: ខ្ញុំធ្លាប់ទៅព្រៃស តែព្រៃសនោះមិនមែនជាគុកទេ ជាកន្លែងកសាង ហើយហ៊ុយស្រែជាប្រធាន នៅព្រៃស។

សស: តែព្រៃសនោះគេហៅលេខប៉ុន្មាន?

ញអ: ភ្លេចហើយ។

សស: លោកថាព្រៃសមិនមែនកន្លែងដាក់អ្នកទោសទេ ហេតុអ្វីបានលោកទៅថតដែរ?

ញអ: ទៅថតដែរ ព្រោះដើម្បីធ្វើប្រវត្តិរូប តែព្រៃសនោះក៏ជារបស់អគ្គសេនាធិការដែរ។

សស: រូបថតនៅព្រៃសដែលមានមកដាក់នៅស-២១ទេ?

ញអ: អត់ដែលមានទេ។

សស: តើមានចាន់ណាផ្សេងទៀតដែលធ្វើការជាមួយម៉ម ណៃទេ?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

00162847

D22/15

ញអ: អត់មានទេ មានតែមួយនោះហើយ តាចាន់នោះកើតឃ្លង់ល្តៅ។

សម្រាកការស្តាប់ចម្លើយសាក្សីនៅម៉ោងដប់ពីរថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល។

ចាប់ផ្តើមការស្តាប់ចម្លើយសាក្សីនៅម៉ោងមួយ និងសាមសិបនាទីថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល។

FL: ការដឹកនាំនៅទួលស្លែង មាននណាឋាន: និងតួនាទីដូចម្តេច ?

ញអ: មេធំជាងគេ តា ឌុច ប្រធាន គាត់ទទួលរួម, តាហ៊ីអនុប្រធានទទួលរួមផ្នែកយោធា, ចាន់សមាជិកទទួលផ្នែកបកប្រែ។ គេហៅថា គណ:ស-២១

សស- ហ៊ុយ ស្រែជាសមាជិកស-២១ ឬ?

ញអ-មិនមែនទេ

FL: អង្គភាពរបស់លោកនៅក្រោមអ្នកណាពិតប្រាកដ? ហើយអ្នកណាបញ្ជាផ្ទាល់លើអង្គភាពថតរូប?

ញអ: នៅក្រោមទាំងបី បញ្ជាផ្ទាល់ទាំងបីនាក់ តែចាន់ទទួលខុសត្រូវផ្ទាល់

FL: តើលោកទាក់ទងទៅឌុចផ្ទាល់ឬទេ?

ញអ: បាទ ធ្លាប់ ពេលគាត់ហៅទៅថតរូបគ្រួសារ ជប់លៀង

FL: តើចាន់បញ្ជាបែបណា?

ញអ: ដូចបាននិយាយពីខាងដើមអញ្ចឹង គឺគាត់បញ្ជាដោយម៉ត់ចត់

សស- ពេលខ្លះទៅថតនៅក្រៅ តើញឹកញាប់ឬទេ? ថតអ្នកណា?

ញអ- មិនសូវជាញឹកញាប់ ១ម្តង ឬ២ដងក្នុង១ខែ ពេលចិនមកទស្សនកិច្ចរោងចក្រប្រេងកាត ឧស្សាហកម្ម កសិកម្ម អង្គរវត្ត ប្រព័ន្ធធារាសាស្ត្រ។ ពេលខ្លះគេហៅមកថតថ្នាក់ដឹកនាំកំពូលៗ។

សស- មានចាំពេលទៅថត?

ញអ- ដូចបានរៀបរាប់ពីព្រឹករួចហើយ។ បានទៅជាមួយគណ:ប្រតិភូជួប អ៊ុំ នួន ពេលចុះទៅមើលសហករ។ ក្នុងក្រុមខ្ញុំមានអ្នកថត៦នាក់ ពេលខ្លះមានការផ្លាស់ប្តូរគ្នា។

សស- មានន័យថា នួន ជានិង ថ្នាក់ដឹកនាំធំៗចុះមូលដ្ឋាន?

ញអ- ចុះទាំងអស់គ្នា តែគ្រាន់តែថាតិចច្រើនមិនដឹងទេ។

សស- តើពេលចុះហ្នឹង លោកឃើញសភាពប្រជាជនយ៉ាងម៉េចដែរ?

ញរ- ការហូបចុកគ្រប់គ្រាន់ ពេលជួបគណ:តំបន់។ តែពេលក្រោយ ៧៩ស្រោប់តែឮថាមានអ្នកអត់បាយ។

សស- នៅក្នុង ស-២១ ធ្លាប់ឃើញ ឌុច សួរទេ?

ញអ- ធ្លាប់ឃើញគាត់សួរម្តង ពេលចាប់អ្នកទោសមកឆ្នាំ៧៧ តាមខ្ញុំដឹងគាត់ចង់បានចំលើយបញ្ជូនទៅអង្គការ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

D22/15

FL: តើលោកឃើញផ្ទាល់ភ្នែកលោកប៉ុន្មានដង?

ញអ: ឃើញម្តង។ ពេលនោះគាត់ជិះម៉ូតូមក ហើយជូនខ្ញុំជិះកង់ ឃើញគាត់វាយនៅមុខទួលស្លែង ព្រោះកន្លែងខ្ញុំធ្វើការនៅទីនោះដែរ ដូច្នេះពេលនោះខ្ញុំឃើញ។

FL: ផ្ទះដូចម្តេចដែរ? នៅផ្នែកខាងណា?

ញអ: ផ្ទះក្បឿង នៅខាងត្បូង

FL: ផ្ទះអ្នកណា?

ញអ: មិនបានចាំ។ ពេលដែលខ្ញុំឃើញនោះផ្ទះនោះចំហ សួរនៅជាន់ក្រោម។

FL: នៅក្នុងផ្ទះលោកឃើញមានពាងទឹកទេ?

ញអ- ខ្ញុំមិនបានដឹងទេ

FL: ពេលខុចសួរចំលើយធ្វើដូចម្តេចខ្លះ?

ញអ: ធ្វើទារុណកម្មដោយវាយនឹងផ្តៅ

សស- លោកឈប់មើល ឬ គ្រាន់តែជិះឃើញ?

ញអ: គ្រាន់តែជិះឃើញ។

FL: ចុះអ្នកនៅចង្ក្រានបាយ ស៊្រុន?

ញអ: ខ្ញុំដើរចូលទៅស៊្រុនបាននិយាយឲ្យខ្ញុំជួយផង នៅពេលដែលគេនាំយកទៅសួរចំលើយ

FL: បន្ទាប់ពីការសួរចំលើយហើយ អ្នកទោសនោះក្លាយទៅជាយ៉ាងណា?

ញអ: អ្នកទាំងនោះមិនអាចត្រឡប់ក្រោយវិញបានទេ ភាគតិចណាស់។ យើងឃើញផ្ទាល់នឹងភ្នែក ឃើញឡានទ្រុងៗមកគេដឹកអ្នកទោសទៅវាយ តែមិនដឹងយកទៅវាយនៅឯណាទេ ព្រោះកន្លែងខ្ញុំនៅ នៅជិតនៅកន្លែងអ្នកទោស។ ពេលដែលឆ្នាំ៩៥ ក្រោយពេលដែលធ្វើសមាហរណកម្មហើយ ទើបឃើញនៅជើងឯក។

FL:ឈ្មោះស្រីគឺជាជាងថតដែរ?

ញអ: ស្រីក៏ខ្ញុំបង្ហាត់ថតដែរ

FL: ស-២១ មានពេទ្យទេ?

ញអ: មានដែរ ឈ្មោះ ប៉ោ ហើយគេវាយចោលដែរ

FL: ពេលលោកនៅជិតពេទ្យមុនីវង្ស តើលោកឃើញឈាមដែលស-២១ បូមយកទៅឲ្យពេទ្យទេ?

ញអ- មិនដែលឃើញទេ។

សស- អ្នកនៅថតក្រុមជាមួយបង មានដែលខុចចាប់មកដាក់គុកទេ?

ញអ- មិនដែលទេ។

សស- ដូចបងរៀបរាប់អ្នកនៅជាមួយគ្នាអ្នកណាខ្លះស្លាប់?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ញអ- អ្នកដែលមកជាមួយខ្ញុំ៧៥ ស្រ៊ិន អ្នកដាំបាយ ចនជាអ្នកយាម។ ចាប់ស្រ៊ិន ឆ្នាំ៧៧ មូលហេតុមកពីចង់បំពុលសម្ដាភាព គឺឌុចជាអ្នកបញ្ជាឲ្យចាប់។ ខ្ញុំដឹងច្បាស់គឺ២នាក់មកពីស្រុកខ្ញុំដែលគេយកទៅសម្លាប់។

FL: លោកបាននិយាយថា គណៈស-២១ មាន ឌុច ហ៊ី ចាន់ តើអ្នកទាំង៣ស៊ីសង្វាក់គ្នាទេ?

ញអ- គឺស៊ីសង្វាក់គ្នា ព្រោះការដឹកនាំមិនអាចឌុចសម្រេចម្នាក់ឯងទេ គឺត្រូវប្រជុំគ្នាដែរ។

FL: ចំពោះតែកិច្ចការពិសេស ឬយ៉ាងណា?

ញអ- ករណីរបស់ខ្ញុំជាករណីពិសេសហើយ។

FL: នៅពេលដែលអ្នកទាំង៣ សម្រេចហើយអ្នកណាជាអ្នកបញ្ជា?

ញអ- គឺគេបញ្ជូនឲ្យអ្នកផ្សេងៗឲ្យសម្រេចការទាំងអស់ បញ្ជូនទៅផ្នែកផ្សេងៗតាមរយៈការសរសេរ ក្នុងនោះមានចុះហត្ថលេខាតាឌុច រួចផ្ញើទៅសុន សេន។ អ្នកដែលស្លាប់នៅស-២១ មានចំនួន១០០០០នាក់ តែបើមិនមានចាន់ ឌុចនិងហ៊ីសម្រេចទេ មិនមានការសម្លាប់ដល់ម្លឹងទេ។

FL: ពេលនោះលោកបានដឹងតួនាទីជាក់លាក់របស់ សុន សេនទេ?

ញង- ខ្ញុំដឹងនៅពេលនោះ គាត់ជារដ្ឋមន្ត្រីក្រសួងការពារជាតិ ទទួលបន្ទុកសន្តិសុខ។

សស- លោក ស្គាល់ ប៉ង់ និង នឿន តើលោកជួបគាត់ទៀតទេ?

ញអ- ខ្ញុំជួបពេលគាត់មកយកឯកសារ។ គាត់យកឯកសារឲ្យប៉ុលពត

សស-ឯកសារអ្វី?

ញអ- ឯកសារជាប្រវត្តិរូប និងចំលើយសារភាព។ រឿងនេះខ្ញុំដឹងច្បាស់ណាស់។ ពេលដែលពួកនេះមក គឺជិះឡានស៊ីបមក។ ក្រោយមក ប៉ង់ស្លាប់នៅភ្នំពេញក្នុងឆ្នាំ៧៨។

FL: កន្លែងណាដែលនឿន និងប៉ង់មក?

ញអ- មកផ្ទះតាឌុច នៅមុខក្រសួងផែនការកន្លែងទូតហុងហ្គារី ផ្ទះខ្ញុំក៏នៅជិតនោះដែរ។

FL: លោកធ្លាប់ចូលផ្ទះឌុចទេ? ធ្លាប់ឃើញឌុចធ្វើទារុណកម្មនៅផ្ទះគាត់ទេ?

ញអ- ធ្លាប់ចូលពេលគាត់ហៅទៅថតប្រពន្ធគាត់ ហើយមិនដែលឃើញគាត់ធ្វើទារុណកម្មនៅផ្ទះគាត់ទេ។

FL: រង្វង់៤ជ្រុងកណ្ដាលជាបរិវេណស-២១ តើលោកអាចគូសកន្លែងសួរចំលើយនៅកន្លែងណាខ្លះ?

ញអ- និយាយរួមកន្លែងសួរចំលើយគឺនៅពេញទីនោះតែម្ដង ប្រហែល១០ ផ្ទះតែវាមានប្លុកច្រើន ហើយប្លុកខ្លះគេមិនឲ្យចូលទេ។

សស- ក្រៅពីប៉ង់ និង នឿន មាននិរសាក្រុងផ្សេងទេ?

ញអ-មិនដែលឃើញអ្នកណាផ្សេងទេ។

សស- តើនៅចាំមុខអ្នកទាំងពីរនោះទេ

ញអ-មិនចាំទេ

FL: លោកនៅស-២១ រហូតដល់ពេលណា?



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

FL

D22115

ញអ- វហូតដល់វៀតណាមចូល។ កាលណោះខ្ញុំមកធ្វើការមក៦ខែ ពាក់កណ្តាល៧៨ គេដកខ្ញុំឱ្យទៅគូសផែនទីសមរភូមិ វៀតណាម នៅស-២១ ពេលនោះខ្ញុំឈប់ថតរូបហើយ។

FL:ក្នុងរយៈពេលចុងក្រោយ តើលោកធ្លាប់ឃើញគេនាំអ្នកទោសមកទៀតទេ?

ញអ- នាំមកតែតិចបំផុត។

FL: ពេលនោះមានគេនាំអ្នកទោសមកស-២១ ដោយមិនបាច់សួរចំលើយហើយសម្លាប់តែម្តង តើលោកដឹងទេ?

ញអ-មិនដឹងទេ។

FL:លោកមានដឹងសល់អ្នកទោសទេ?

ញអ- ខ្ញុំមិនបានដឹងទេ។

FL: មុនភ្លាមៗ ៧មករា ៧៩ លោកឃើញអ្នកធំៗ មកទេ?

ញអ- សុន សេន ហៅមកប្រជុំ ពេលនោះគេឱ្យត្រៀមដឹកត្រង់សេ ពេលនោះសុន សេន បញ្ជាឱ្យគូសផែនទី ហើយពេលនោះវៀតណាមវាយចូលដល់ក្រចេះ។

FL: លោកបានដឹងថាទ័ពយួនបានចូលដល់កន្លែងណាៗ តើដឹងមកពីណា?

ញអ- គណៈបញ្ជាការគ្រប់មុខព្រួញ គេផ្តល់ព័តមានមក សុន សេន គឺសុន សេន មកផ្ទាល់ គឺពួកខ្ញុំ១២នាក់ ក្រុមនេះដកមកពីខាង ជាងថត៣នាក់។

សស- សុន សេន មកប្រជុំស-២១ ទាំងអស់គ្នា ឬ?

ញអ- គឺប្រជុំទាំងអស់ ឱ្យត្រៀមប្រយុទ្ធជាមួយទ័ពវៀតណាម។

សស-ពេលនោះ ថ្ងៃ១ មករា ៧៩ គេនិយាយពីអ្នកទោសនៅស-២១ ត្រូវធ្វើយ៉ាងម៉េច?

ញអ- នៅឆ្នាំ៧៧ គឺខ្ញុំដឹង តែក្រោយមកមិនដឹងតែម្តង។ កម្លាំងស-២១ ទាំងអស់រត់តាមទួលទំពូង ស្ពានទូតចិន កន្ទួត មានឌុច មានចាន់ មានឆែន កម្លាំងបែកគ្នាពាក់កណ្តាលនៅកន្ទួត ព្រោះរថក្រោះបញ្ឈរនៅទីនោះ ហើយខ្ញុំបានបែកកម្លាំងគ្នានៅ ខេត្តកំពង់ស្ពឺ។

FL: ក្រោយមកឌុចគាត់ទៅណា?

ញអ- ខ្ញុំមិនដឹងទេ តែបែកខែ២ ឆ្នាំ៧៩ នៅថ្មគប់ អន្លង់ជ្រៃ មិនដែលបានដឹងគាត់ដឹងសោះ។

FL: លោកមានដឹងទេថា ក្នុងជំនាន់នោះ មានគេទុកអ្នកទោសសម្រាប់ធ្វើការងារផ្សេងៗទេ?

ញអ- មិនដឹងទេ។

FL: តាណាតជាអ្នកទោស ឬអ្នកគូសរូប?

ញអ-គាត់អ្នកអ្នកទោស។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

☒ឯកសារថតចម្លងនៃកំណត់ហេតុមួយច្បាប់ត្រូវបានប្រគល់ឱ្យសាក្សីនេះ។

បញ្ចប់ការស្តាប់ចម្លើយរបស់សាក្សីនៅម៉ោងបួន និងដប់ពីរនាទី ថ្ងៃខែឆ្នាំដដែល។

សាក្សីបានផ្តល់រូបថតចំនួនបីសន្លឹក និងសៀវភៅរៀនបច្ចេកទេសថតកាលគាត់រៀននៅប្រទេសចិន។

☒អានឱ្យស្តាប់ហើយ សាក្សី មិនមានជំទាស់អ្វីទេ ហើយសុខចិត្តចុះហត្ថលេខា។

☐ អានឱ្យស្តាប់ហើយ សាក្សី មិនព្រមចុះហត្ថលេខាទេ។

| សាក្សី | អ្នកបកប្រែ | អ្នកស៊ើបអង្កេត |
|---|---|---|
| **Witness** | **Interpreter** | **Investigators** |
| **Témoin** | **Interprète** | **Enquêteurs** |



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។

Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941